សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត

នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

# សារលិខិត

## សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត
## នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
## ក្នុងឱកាសទិវាជាតិគ្រប់គ្រងគ្រោះមហន្តរាយ
## ថ្ងៃទី១៣ ខែតុលា ឆ្នាំ២០២៣

- សូមក្រាបថ្វាយបង្គំសម្តេចព្រះមហាសង្ឃរាជទាំងពីរគណៈ ព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គជាទីសក្ការៈ!
- សម្តេច ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា ឧកញ៉ា លោក លោកស្រី!
- បងប្អូនជនរួមជាតិជាទីមេត្រី!

ក្នុងនាមរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ទូលព្រះបង្គំខ្ញុំ ខ្ញុំព្រះករុណាខ្ញុំ សូមសម្តែងនូវមនោសញ្ចេតនារីករាយ និងគាំទ្រចំពោះការរៀបចំប្រារព្ធទិវាជាតិគ្រប់គ្រងគ្រោះមហន្តរាយ ក្រោមប្រធានបទ .វិនិយោគពីថ្នាក់ជាតិនូវភាពធន់សហគមន៍. រួមជាមួយទិវាអាស៊ានគ្រប់គ្រងគ្រោះមហន្តរាយ និងទិវាអន្តរជាតិកាត់បន្ថយគ្រោះមហន្តរាយ ថ្ងៃទី១៣ ខែតុលា ឆ្នាំ២០២៣។

ទូលព្រះបង្គំខ្ញុំ ខ្ញុំព្រះករុណាខ្ញុំ សូមយកឱកាសដ៏វិសេសវិសាលនេះថ្លែងនូវសារលិខិតថ្វាយសម្តេចព្រះសង្ឃរាជ ប្រគេនព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ និងជូនបងប្អូនជនរួមជាតិទាំងអស់ ក្នុងបំណងលើកកម្ពស់ស្មារតីយល់ដឹងនៃការអនុវត្តភារកិច្ចគ្រប់គ្រងគ្រោះមហន្តរាយ ក្នុងក្របខណ្ឌពហុវិស័យ ដោយឈរលើគ្រប់ទិដ្ឋភាពនៃសេដ្ឋកិច្ចសង្គម និងប្រកបដោយបរិយាបន្ន។

ក្នុងទិវាដ៏ថ្លៃថ្លានេះ ទូលព្រះបង្គំជាខ្ញុំសូមព្រះបរមរាជានុញ្ញាតសម្តែងគារវភក្តី និងកតញ្ញុតាធម៌ដ៏ជ្រាលជ្រៅបំផុតថ្វាយ **ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា និងសម្តេចព្រះមហាក្សត្រី នរោត្តម មុនីនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ** ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត ដែលជានិច្ចកាលព្រះអង្គទាំងទ្វេតែងបានយកព្រះទ័យទុកដាក់ខ្ពស់ចំពោះសុខទុក្ខប្រជារាស្ត្រជាកូនចៅ ចៅទួតរបស់ព្រះអង្គ ដោយក្តីអាណិតស្រឡាញ់ និងប្រោសព្រះរាជទាននូវអំណោយដ៏ថ្លៃថ្លាជួយដល់ប្រជារាស្ត្រ កូនចៅទីទ័លក្រ និងរងគ្រោះដោយគ្រោះមហន្តរាយផ្សេងៗ។

ខ្ញុំសូមសម្តែងនូវកតញ្ញុតាធម៌ជូនចំពោះ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** អតីតនាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដែលលោកបានការពារយ៉ាងមោះមុតនូវសុខសន្តិភាព និងសុវត្ថិភាពជូនប្រជាជន ដឹកនាំការគ្រប់គ្រងគ្រោះមហន្តរាយ ដោយប្រយុទ្ធ ទប់ស្កាត់ រក្សាការពារអាយុជីវិត និងជីវភាពប្រជាជន ដោយមិនទុកឱ្យប្រជាជនណាម្នាក់ស្លាប់ដោយមិនមានការទទួលខុសត្រូវឡើយ។

ជាមួយនេះដែរ ខ្ញុំព្រះករុណាខ្ញុំ ក៏សូមថ្លែងនូវអំណរព្រះគុណប្រគេនព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ និងអរគុណជូនចំពោះសម្តេច ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា ឧកញ៉ា ថ្នាក់ដឹកនាំក្រសួងស្ថាប័ន មន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធ កាកបាទក្រហមកម្ពុជា ដៃគូអភិវឌ្ឍន៍ អង្គការជាតិ អន្តរជាតិ ផ្នែកឯកជន សប្បុរសជន និងប្រទេសជាមិត្តដែលបានឧបត្ថម្ភគាំទ្រ និងបរិច្ចាគធនធាន សម្ភារ ថវិកា ជួយដល់ប្រជាជនកម្ពុជាទទួលរងនូវគ្រោះមហន្តរាយ ដែលកើតមានលើទឹកដីកម្ពុជាកន្លងមក។

**ព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ បងប្អូនជនរួមជាតិ ជាទីមេត្រី!**

ជាការពិតស្ថានភាពសេដ្ឋកិច្ច សង្គមពិភពលោកបច្ចុប្បន្ន បានរងផលប៉ះពាល់ពីការកើតមាននៃជំងឺកូវីដ-១៩ និងជម្លោះដែលកំពុងកើតមានរវាងរុស្ស៊ី និងអ៊ុយក្រែន ហើយជាមួយនោះពិភពលោកក៏ជួបនូវកត្តានៃការប្រែប្រួលអាកាសធាតុ នាំឱ្យមានការកើនឡើងកំដៅផែនដីបន្តជះឥទ្ធិពលអវិជ្ជមានដល់បរិស្ថានពិភពលោកទាំងមូល និងបង្កឱ្យកើតមានគ្រោះមហន្តរាយធម្មជាតិ ធ្វើឱ្យបាត់បង់អាយុជីវិត ខូចខាតទ្រព្យសម្បត្តិ ហេដ្ឋារចនាសម្ព័ន្ធ សេដ្ឋកិច្ចសង្គមយ៉ាងធ្ងន់ធ្ងរ នៅក្នុងប្រទេសជាច្រើនមិនថាជាប្រទេសអភិវឌ្ឍន៍ ប្រទេសកំពុងអភិវឌ្ឍន៍ ឬប្រទេសក្រីក្រនោះឡើយ។

ដោយឡែកព្រះរាជាណាចក្រកម្ពុជា ក៏មិនខុសពីប្រទេសនៅក្នុងតំបន់ និងនៅលើពិភពលោកនេះដែរ ស្ថានភាពអាកាសធាតុដូចជាការកើនឡើងកម្តៅ រដូវវស្សាជួបនឹងរបាយទឹកភ្លៀងធ្លាក់មិនបានរាយប៉ាយល្អ ហើយមុខសញ្ញាគ្រោះថ្នាក់ដូចជា ខ្យល់កន្ត្រាក់ រន្ទះបាញ់ បាក់ច្រាំងទន្លេ ជំងឺឆ្លងរាតត្បាត និងព្រឹត្តិការណ៍មិនធម្មតា ជំងឺកូវីដ-១៩ អគ្គិភ័យ គ្រោះថ្នាក់ផ្លូវគោក ផ្លូវទឹក រលំបាក់អគារ មុខសញ្ញាគ្រោះថ្នាក់ផ្សេងៗទៀតបានផ្តាច់អាយុជីវិតមនុស្ស ខូចខាតទ្រព្យសម្បត្តិប្រជាជន សហគមន៍ជាច្រើន។ ទោះបីជាមានមុខសញ្ញាគ្រោះថ្នាក់គ្រោះមហន្តរាយនៅតែបន្តកើតមានក៏ដោយ រាជរដ្ឋាភិបាលតែងតែប្រើប្រាស់គ្រប់វិធានការសេរុប មធ្យោបាយសេរុប ដើម្បីកាត់បន្ថយហានិភ័យគ្រោះមហន្តរាយមកលើប្រជាជន។

ក្នុងឆ្នាំ២០២៣ ជាឆ្នាំដែលកម្ពុជាទទួលបានជោគជ័យពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ នៃរដ្ឋសភា នាថ្ងៃទី២៣ ខែកក្កដាកន្លងទៅនេះ ដែលប្រជាពលរដ្ឋយើងជាង ៨០% បានទៅបោះឆ្នោតក្នុងចំណោមប្រជាពលរដ្ឋដែលមានឈ្មោះក្នុងបញ្ជីបោះឆ្នោត។ នេះសបញ្ជាក់ឱ្យឃើញអំពីស្មារតីប្រកបដោយឆន្ទៈ និងការប្តេជ្ញាចិត្តខ្ពស់របស់ប្រជាពលរដ្ឋ ក្នុងការជ្រើសតាំងគណបក្សនយោបាយ ដែលខ្លួនពេញចិត្តសម្រាប់ដឹកនាំរាជរដ្ឋាភិបាល ហើយក៏បានផ្តល់សេចក្តីទុកចិត្តបោះឆ្នោតជូនគណបក្សប្រជាជនកម្ពុជាឱ្យបន្តដឹកនាំរាជរដ្ឋាភិបាល ដើម្បីធានាការពារសន្តិភាព និងការអភិវឌ្ឍរបស់ប្រទេសជាតិ ដែលប្រជាជនកម្ពុជាបានយល់ដឹង បានឆ្លងកាត់កន្លងមក ពីប្រទេសខ្ទេចខ្ទាំដោយគ្រោះមហន្តរាយធំធេងបង្កដោយមនុស្សគឺ «សង្គ្រាម» និងរបបប្រល័យពូជសាសន៍ ហើយបច្ចុប្បន្នបានក្លាយជាប្រទេសដែលស្ថិតក្រោមដំបូលសន្តិភាពពេញបរិបូរណ៍ ក្នុងនាមជាប្រជាជាតិមួយដែលកំពុងបន្តដំណើររួមគ្នាឆ្ពោះទៅរកអនាគតរុងរឿង។

ឈរលើបុព្វហេតុដ៏ឧត្តុង្គឧត្តមខាងលើ រាជរដ្ឋាភិបាលកម្ពុជា នឹងបន្តផ្តល់អាទិភាពខ្ពស់លើការគ្រប់គ្រងគ្រោះមហន្តរាយ ដោយពុះពារប្រយុទ្ធលើគ្រប់សមរភូមិ ម្ចាស់ការឱ្យបានលើគ្រប់ទិដ្ឋភាព និងគ្រប់កាលៈទេសៈនៃហេតុការណ៍គ្រោះមហន្តរាយ ដោយផ្សារភ្ជាប់ការគ្រប់គ្រងគ្រោះមហន្តរាយទៅនឹងការអភិវឌ្ឍនៅមូលដ្ឋានធ្វើយ៉ាងណាធានាជំរុញលំហូរធនធានឱ្យបានកាន់តែលឿនដល់ការគ្រប់គ្រងគ្រោះមហន្តរាយនៅថ្នាក់ក្រោមជាតិ។

ព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គបងប្អូនជនរួមជាតិ ជាទីមេត្រី!

ប្រធានបទ «វិនិយោគពីថ្នាក់ជាតិនូវភាពធន់សហគមន៍» ដែលត្រូវបានលើកយកមកប្រារព្ធទិវាជាតិគ្រប់គ្រងគ្រោះមហន្តរាយនាពេលនេះ ពិតជាមានខ្លឹមសារសំខាន់ និងស័ក្តិសមបំផុតក្នុងការឆ្លើយតបទៅនឹងភាពចាំបាច់និងតម្រូវការជាក់ស្តែងរបស់ស្ថាប័ន និងប្រជាជនកម្ពុជា ក្នុងការបន្តរក្សានិងបង្កើនភាពធន់ទៅនឹងគ្រោះមហន្តរាយ ដើម្បីភូមិ ឃុំ សង្កាត់ មានសុវត្ថិភាព អភិវឌ្ឍន៍ជីវភាពរស់នៅ និងភាពសុខដុមនៅក្នុងសហគមន៍។

ជាមួយនោះទិវាជាតិគ្រប់គ្រងគ្រោះមហន្តរាយ រួមជាមួយទិវាអាស៊ានគ្រប់គ្រងគ្រោះមហន្តរាយ និងទិវាអន្តរជាតិសម្រាប់ការកាត់បន្ថយគ្រោះមហន្តរាយ គឺជាការផ្សារភ្ជាប់នូវកិច្ចខិតខំប្រឹងប្រែងថ្នាក់ជាតិ រួមជាមួយថ្នាក់តំបន់ និងអន្តរជាតិ អំពីសារៈសំខាន់នៃការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ និងការបង្ហាញអំពីជំហរការប្តេជ្ញាចិត្ត និងសាមគ្គីភាពរបស់ប្រជាជាតិអាស៊ាន ក្នុងការរួមគ្នាគ្រប់គ្រងគ្រោះមហន្តរាយ តាមរយៈការអនុវត្តកិច្ចព្រមព្រៀងអាស៊ានស្តីពីការគ្រប់គ្រងគ្រោះមហន្តរាយ និងការឆ្លើយតបសង្គ្រោះបន្ទាន់ ក្នុងស្មារតីការលើកកម្ពស់ **អាស៊ានតែមួយ ការឆ្លើយតបតែមួយ** ហើយក៏ជាការបញ្ជាក់ពីការប្តេជ្ញាចិត្តខាងនយោបាយ ចូលរួមក្នុងបេសកកម្មកាត់បន្ថយឱ្យបានច្រើនគួរសមពីហានិភ័យគ្រោះមហន្តរាយ ការបាត់បង់អាយុជីវិត ជីវភាពរស់នៅ និងនៅក្នុងសេដ្ឋកិច្ច សង្គម សុខភាព វប្បធម៌ និងបរិស្ថាន ទ្រព្យសម្បត្តិបុគ្គល សហគមន៍ និងប្រទេស ស្របតាមក្របខណ្ឌការងារសេនដាយសម្រាប់ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយឆ្នាំ២០១៥-២០៣០។

ការគ្រប់គ្រងគ្រោះមហន្តរាយ ជាការងារពហុវិស័យ ជាការងារប្រទាក់ក្រឡាពាក់ព័ន្ធស្ទើរគ្រប់ទិដ្ឋភាពសេដ្ឋកិច្ច សង្គម របស់ប្រទេសជាតិ ដែលត្រូវធ្វើឡើងប្រកបដោយបរិយាបន្ន។ ហេតុនេះមិនថាវិស័យណាមួយ ស្ថាប័នណាមួយ ឬផ្នែកណាមួយ ទាំងស្ថាប័នរដ្ឋ ឯកជន គិតទាំងបុគ្គលគ្រប់រូបសុទ្ធតែមានភារកិច្ចនិងជាប់ពាក់ព័ន្ធរួមចំណែកដោយផ្ទាល់ ឬដោយប្រយោលទៅក្នុងការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ ដើម្បីភាពធន់ និងការអភិវឌ្ឍប្រកបដោយចីរភាព។

ក្នុងន័យនេះ គ្រប់ភាគីពាក់ព័ន្ធទាំងអស់គឺមានតួនាទីក្នុងការចូលរួមធ្វើសកម្មភាពកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ ដោយធ្វើការវិនិយោគភាពវៃឆ្លាតគឺការវិភាជន៍ទុន និងធនធានដោយផ្ទាល់ ដើម្បីធ្វើសមាហរណកម្មការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយនៅក្នុងការអភិវឌ្ឍសហគមន៍។

ដើម្បីជំរុញឱ្យប្រធានបទដូចបានកំណត់ខាងលើក្លាយជាការពិតជាក់ស្តែង ខ្ញុំព្រះករុណាខ្ញុំ សូមយកឱកាសនៃទិវាជាតិគ្រប់គ្រងគ្រោះមហន្តរាយ ថ្ងៃទី១៣ ខែតុលា ឆ្នាំ២០២៣នេះ ធ្វើការអំពាវនាវជូនជនរួមជាតិដូចតទៅ៖

*១. បន្តការយកចិត្តទុកដាក់រួមចំណែកជាមួយរាជរដ្ឋាភិបាល ក្នុងការរក្សាកំណើនសេដ្ឋកិច្ច តាមរយៈការចូលរួមវិនិយោគវៃឆ្លាតកែលម្អលំនៅឋាន ទីតាំងអាជីវកម្មឱ្យមានសុវត្ថិភាព ពង្រីកមុខរបរដែលធន់ ដើម្បីរក្សាស្ថិរភាព ជីវភាពរស់នៅជាប្រក្រតីតាមគន្លងថ្មី ជាមួយការរស់នៅស្អាត បរិស្ថានល្អ និងភូមិ ឃុំ សង្កាត់ មានសុវត្ថិភាព ព្រមទាំងប្រកាន់ភ្ជាប់ជាមួយវប្បធម៌ចែករំលែក។*

*២. លើកកម្ពស់វប្បធម៌ផ្ទេរ ទទួលយក និងចែករំលែកចំណេះដឹង ចំណេះធ្វើ និងបទពិសោធន៍ក្នុងការទប់ស្កាត់ការកាត់បន្ថយគ្រោះមហន្តរាយ និងបន្តពង្រឹងសមត្ថភាពលើការយល់ដឹងអំពីហានិភ័យគ្រោះមហន្តរាយ តាមរយៈការយកចិត្តទុកដាក់តាមដានមុខសញ្ញាគ្រោះថ្នាក់ ព័ត៌មានព្យាករណ៍ និងការប្រកាសឱ្យដឹងមុនអំពីហេតុការណ៍ និងគ្រោះថ្នាក់ដែលអាចកើតមានដោយគ្រោះមហន្តរាយ។*

៣. *ក្រសួងស្ថាប័នផ្សេ ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ត្រូវកំណត់ថា ការងារគ្រប់គ្រងគ្រោះមហន្តរាយ ជាការងារស្នូលរបស់ខ្លួន និងពង្រឹងលេខាធិការដ្ឋានគ្រប់គ្រងគ្រោះមហន្តរាយ ដែលជាសេនាធិការ ធានាឱ្យមានធនធានមនុស្ស សម្ភារ សម្រាប់បំពេញការងារ មានធនធានសម្រាប់ដំណើរការ ការងារឆ្លើយតប និងស្តារឡើងវិញក្រោយគ្រោះមហន្តរាយ។*

៤. *ក្រសួងស្ថាប័ន និងអាជ្ញាធរគ្រប់លំដាប់ថ្នាក់បន្តពង្រឹងយន្តការ គោលនយោបាយ យុទ្ធសាស្ត្រ កម្មវិធី ផែនការ និងសកម្មភាពដែលមានស្រាប់ដោយបញ្ជ្រាបការគ្រប់គ្រងគ្រោះមហន្តរាយ និងការប្រែប្រួលអាកាសធាតុ ដើម្បីពង្រឹងភាពធន់ផ្នែកសេដ្ឋកិច្ច សង្គម សុខភាព និងបរិស្ថាន។*

ព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ បងប្អូនជនរួមជាតិ ជាទីមេត្រី!

ទូលព្រះបង្គំ ខ្ញុំព្រះករុណាខ្ញុំ សង្ឃឹមថាខ្លឹមសារ និងអត្ថន័យនៃសារលិខិតនេះនឹងស្ថិតនៅជានិច្ចក្នុងស្មារតីរបស់យើងទាំងអស់គ្នា ដើម្បីបុព្វហេតុសុខសន្តិភាព និងការអភិវឌ្ឍរបស់ប្រទេសជាតិ។ ខ្ញុំជឿជាក់ថា ទិវាជាតិគ្រប់គ្រងគ្រោះមហន្តរាយ ថ្ងៃទី១៣ ខែតុលា ឆ្នាំ២០២៣នេះ នឹងជួយរំលឹកយើងជាថ្មីម្តងទៀត ឱ្យចងចាំអំពីអតីតកាលដ៏ឈឺចាប់នៃសង្គ្រាមដែលជាគ្រោះមហន្តរាយ បង្កដោយមនុស្ស និងប្តេជ្ញាការពារ ថែរក្សាឱ្យខាងតែបាននូវដំបូលសន្តិភាពដែលជាគ្រឹះមិនអាចខ្វះបានសម្រាប់ការអភិវឌ្ឍ និងភាពសុខសាន្តរបស់ប្រជាជន។

ជាទីបញ្ចប់ ទូលបង្គំ ខ្ញុំព្រះករុណាខ្ញុំ សូមថ្វាយ និងប្រគេនពរដល់ព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ និងសូមជូនពរ សម្តេច ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា ឧកញ៉ា លោក លោកស្រី បងប្អូនជនរួមជាតិទាំងអស់ សូមបានប្រកបដោយពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

ថ្ងៃ ចន្ទ ៤ កើត ខែភទ្របទ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០២៣

ហ៊ុន ម៉ាណែត